# ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## ប្រកាស

ភ្នំពេញ , ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣

## ប្រកាស លេខ ០៥៣ សធករប្រក

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១១ - ១១ - ៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី
- បានឃើញសារាចរលេខ ០០២ សរណន.គម.គពឈ ចុះថ្ងៃទី ១៨ - ១២ - ៨៩ កំណត់ការងារគ្រប់គ្រងយានជំនិះផ្លូវគោក ផ្លូវទឹក ។
- បានឃើញប្រកាសលេខ ០៩៣ ប្រក.គម.គពឈ ចុះថ្ងៃទី ១០ - ៣ - ៩២ ស្តីពីការកែប្រែសារាចរណែនាំអំពីការងារគ្រប់គ្រងយានជំនិះផ្លូវគោក ផ្លូវទឹក ។
- បានឃើញលិខិតលេខពិសេស ចុះថ្ងៃទី ២២ - ១១ - ៩៣ ស្តីពីការសំរេចរបស់គណៈរដ្ឋមន្ត្រីអោយចន្លយការប្រើប្រាស់ផ្លាកលេខយន្តផ្សេង ៗ
- បានឃើញសេចក្តីសំរេច នៃអង្គប្រជុំអន្តរក្រសួងនៅក្រសួងសាធារណការ និង ដឹកជញ្ជូនពីថ្ងៃទី ១៣ - ១២ - ៩៣ ស្តីពីការកំណត់ផ្លាកលេខយានយន្ត

## សំរេច

**ប្រការ ១ :** យានយន្តគ្រប់ប្រភេទរបស់សាធារណជនទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលគន្លងមកពាក់ផ្លាកលេខ ដែលផ្តល់អោយដោយក្រសួង និង ស្ថាប័នផ្សេង ៗ បណ្តាលអោយមានភាពស្មុគ្រស្មាញ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម បញ្ហាសន្តិសុខ ពន្ធដារ ។ល។ ត្រូវតែប្តូរផ្លាកលេខតាមសញ្ញាថ្មី ។

ប្រការ ២ : ក្រសួងសាធារណការ និង ដឹកជញ្ជូន ( ការិយាល័យពិនិត្យយានយន្ត ) ត្រូវចុះបញ្ជីការ និង ផ្តល់ ផ្លាកលេខជាថ្មីសំរាប់យានយន្តគ្រប់ប្រភេទ ដែលបើកបរលើផ្លូវសាធារណៈទូទាំងរាជាណាចក្រកម្ពុជា ។ ដោយឡែកផ្លាកលេខសំរាប់ទោចក្រយានយន្ត ត្រាក់ទ័រ និងរ៉ឺម៉ក តាមបណ្តាខេត្ត ក្រុង ត្រូវចេញអោយមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត ក្រុង ។

ប្រការ ៣ : ម្ចាស់យានយន្ត ទោចក្រយានយន្ត ដែលមានពាក់ផ្លាកលេខផ្សេងៗ ចេញអោយដោយក្រសួង និង ស្ថាប័ននានា ត្រូវតែមកបំពេញបែបបទ និង សុំផ្លាកលេខជាថ្មីនៅការិយាល័យត្រួតពិនិត្យយានយន្ត នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ។ ចំពោះទោចក្រយានយន្ត ត្រាក់ទ័រ និង រ៉ឺម៉ក ត្រូវធ្វើតាម មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត ក្រុង ចាប់ពី ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៤ ជាកំណត់ ។

ប្រការ ៤ : ម្ចាស់យានយន្ត និង ទោចក្រយានយន្តទាំងឡាយណាដែលមិនបានអនុវត្ត តាមប្រកាសនេះទេ នឹង ត្រូវមានវិធានការឃាត់ទុកមធ្យោបាយ ហើយនិងត្រូវផាកពិន័យតាមច្បាប់ជាធរមាន ។

ប្រការ ៥ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : លោកអគ្គនាយក នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

**ទេសរដ្ឋមន្ត្រី**

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និង ត្រា

**អ៊ឹង គៀត**

****